អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# តើអ្នកពូកែអ្វី?

# What are you good at?






សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

Written by TukTuk

Illustrated by Choven Hen

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



នារសៀលថ្ងៃមួយ យ៉េកកំពុងដឹកខេទីនិងលោកគ្រូសុខនៅលើរ៉ឺម៉កកង់បីរបស់គាត់ ដើម្បីជិះដើរលេង។ ស្រាប់តែពួកគាត់បានប្រទះឃើញរតនានិងមករាកំពុងលេងនៅតាមផ្លូវ។

ខេទីក៏ស្រែកសួរ « តើអ្នកទាំងពីរចង់ឡើងមកជិះរ៉ឺម៉កកង់បី ដើរលេងជាមួយពួកយើងដែរឬទេ? »

ឮដូចនេះ កុមារទាំងពីរនាក់សប្បាយត្រេកអរយ៉ាងខ្លាំង ហើយក៏ហក់ឡើងរ៉ឺម៉កកង់បី ជាមួយពួកគេតែម្តង។




ខណៈពេលដែលពួកគាត់ទាំងអស់គ្នា កំពុងជិះរ៉ឺម៉កកង់បីដើរលេង ស្រាប់តែរតនាប្រាប់យ៉េកនិងខេទី
« ខ្ញុំពូកែគណិតណាស់។ ថ្ងៃនេះ ថ្នាក់របស់ខ្ញុំប្រឡង ហើយខ្ញុំបានលេខមួយទៀតហ៎! »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




មករាក៏និយាយ « ឯខ្ញុំវិញពូកែភាសាខ្មែរ ខាងប្រកបពាក្យខ្លាំងណាស់។
ថ្ងៃនេះ ថ្នាក់របស់ខ្ញុំក៏ប្រឡងដែរ ហើយខ្ញុំប្រកបត្រូវគ្រប់ពាក្យ។ ចុះយ៉េកវិញពូកែខាងអ្វីដែរ? »



យ៉េកឆ្លើយ « ខ្ញុំខ្ពស់ ហើយខ្ញុំអាចឈោងដៃដល់កន្លែងខ្ពស់ៗជាច្រើន »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



លោកគ្រូសុខក៏ឆ្លើយដែរ « លោកគ្រូវិញមានកម្លាំងខ្លាំង។ លោកគ្រូអាចលើករបស់ធ្ងន់ៗបានជាច្រើន »



ចំណែកឯ ខេទីវិញនៅស្ងៀម។

« ចុះខេទីវិញ? តើអ្នកពូកែខាងអ្វីដែរ? »

ខេទីគិតមួយសន្ទុះ រួចក៏សម្រេចចិត្តឆ្លើយទាំងទឹកមុខស្រពាប់ស្រពោន « ខ្ញុំគិតថា ខ្ញុំដូចជាអត់មានពូកែខាងអ្វីសោះហើយ »



និយាយដល់ត្រឹមនេះ ពួកគាត់ក៏ជិះមកដល់កន្លែង ដែលលោកគ្រូសុខចូលចិត្តមកអង្គុយលំហែកាយលេង។
លោកគ្រូសុខក៏បាននិយាយ « ឱ្យតែលោកគ្រូមានពេលទំនេរ លោកគ្រូចូលចិត្តមកទីនេះលេងហើយ »។
មករាលាន់មាត់ « ខ្ញុំស្រេកទឹកណាស់ »
រតនាក៏ឆ្លើយ « អូ! អត់បានទេ » រតនានិយាយទាំងយំ « យើងភ្លេចយកទឹកមកបាត់ទៅហើយ។ តើគួរធ្វើយ៉ាងណាទៅ? »



មករាក៏មានយោបល់ « ប្រហែលជាពួកយើងអាចបេះផ្លែដូងនៅដើមនេះបាន។ តើធ្វើយ៉ាងណាទើបបេះផ្លែដូងបានទៅណ៎? »




រតនារាប់ផ្លែដូងទាំងអស់ ដែលនៅលើដើមដូងនោះ។ នាងក៏បូកដកឃើញថា បើពួកគេអាចបេះដល់ ពួកគេនឹងបានផ្លែដូងម្នាក់មួយ ហើយនៅសល់ដូងពីរផ្លែទៀតផង តែបូកដកបែបនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាននោះទេ។




រតនារាប់ផ្លែដូងទាំងអស់ ដែលនៅលើដើមដូងនោះ។ នាងក៏បូកដកឃើញថា បើពួកគេអាចបេះដល់ ពួកគេនឹងបានផ្លែដូងម្នាក់មួយ ហើយនៅសល់ដូងពីរផ្លែទៀតផង តែបូកដកបែបនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាននោះទេ។



យ៉េកខំឈរចង្អើត លើកដៃឈោងទៅលើ តែទោះជាគាត់អាចលើកដៃបានខ្ពស់ប៉ុណ្ណាក៏ដោយ ក៏មិនខ្ពស់ដល់ថ្នាក់អាចបេះផ្លែដូងបានដែរ។



លោកគ្រូសុខឱនក្បាលចុះ ហើយរត់សម្រុកទៅបុកដើមដូងពេញមួយទំហឹង។
គាត់គិតថា ធ្វើយ៉ាងនេះអាចធ្វើឱ្យផ្លែដូងរង្គើធ្លាក់ចុះក្រោម។ តែចុងក្រោយ បែរជាគ្មានផ្លែដូងណាធ្លាក់មក សូម្បីតែមួយផ្លែសោះ។




ស្រាប់តែពេលនោះ មានដូងមួយផ្លែធ្លាក់មកក្លុក នៅជិតរតនាតែម្ដង  ធ្វើឱ្យពួកគាត់លោតភ្ញាក់ខ្លួនគ្រប់ៗគ្នា។

« ក្លុក! » ដូងមួយផ្លែទៀតធ្លាក់មកជិតមករាហើយ!

« ក្លុកៗ! »

« តើមានរឿងអ្វីកើតឡើងហ្នឹង? »



ពួកគេក៏នាំគ្នាងើយមើលទៅលើទាំងអស់គ្នា ឃើញខេទីនៅលើដើមដូង កំពុងបេះផ្លែដូងជិតបានមួយផ្លែទៀតហើយ!
« ក្អក! »
តោះទះដៃឱ្យខេទីទាំងអស់គ្នា ព្រោះគាត់បានជួយសង្គ្រោះអ្នកទាំងអស់គ្នា ពីការស្រេកទឹកនៅគ្រានេះបានហើយ។



រតនាក៏និយាយ « ឃើញអត់ខេទី តាមពិតអ្នកពូកែទេតើ គឺពូកែខាងឡើងដើមឈើនោះអី »
មករាក៏និយាយបន្ត « មនុស្សម្នាក់ៗសុទ្ធតែពូកែមួយរឿងផ្សេងៗពីគ្នា »៕